

# គោលវិធីដ៏កំរោល

## Une méthode grossière

កិច្ចព្រមព្រៀង ស្តីពីការរកសុខផ្ទាល់ខ្លួន នៃក្រុមអ្នកនយោបាយនៅស្រុកខ្មែរ រវាងគណបក្សសង្គ្រោះចោរ និង គណបក្សចោរលួចជាតិ កាលពីថ្ងៃទី២២កក្កដាទើបតែកន្លងមកនេះ វាគ្មានអ្វីនាំឲមានការផ្ទាក់ផ្អើល (វិស្ម័យ) សំរាប់អ្នកប្រជាធិបតេយ្យនោះឡើយ ព្រោះកិច្ចព្រមព្រៀងនេះ វាច្បាស់ជាត្រូវកើតមានជាពុំខាននៅពេលណាមួយនោះឯង រវាងជនទុច្ចរិត ដើម្បីការពារប្រយោជន៍វា តែការដែលគ្មាននរណាម្នាក់ អាចនឹកស្មានដល់ គឺជម្រើសនៃគោលវិធីដ៏កំរោលមួយ យកវាមកអនុវត្តនៅក្នុងកាលៈទេសៈនៃនិគ្រោះ (répression) ជាក់ស្តែងពីសំណាក់គណបក្សចោរលួចជាតិ រណបយួន ៖ បិទទីលានប្រជាធិបតេយ្យ, បិទសេរីភាពបញ្ចេញមតិ, ចាប់អ្នកតំណាងគណបក្សសង្គ្រោះចោរដាក់គុកព្រៃស តាមតែទំនើងចិត្ត។ល។

បើយើងលើកយកប្រការ៧ចំណុច មាននៅក្នុងហិរិកិច្ចព្រមព្រៀង (accord honteux) នេះមកពិនិត្យ យើងឃើញគ្មានមានប្រការណាមួយ ស្តីពីការរំដោះសេរីភាពប្រជាពលរដ្ឋ, ការពារលទ្ធិប្រជាធិបតេយ្យ, រកយុត្តិធម៌ជូនម្ចាស់ឆ្នោត និង គ្រប់ជនរងគ្រោះពីនយោបាយផ្តាច់ការនៃរាជរដ្ឋាភិបាលនោះឡើយ និង គ្មានទស្សនវិស័យអភិវឌ្ឍន៍ សំរាប់ភាពចំរើន នៃសង្គម ក្រៅតែពីរបៀបចែកតួនាទីគ្នា រវាងជនទុច្ចរិតតែប៉ុណ្ណោះ ផ្ទុយទៅវិញ អំណាច ហ៊ុន-សែន នៅមានគ្រប់សារពើឋាន (omniprésence) សង្កត់លើក្បាល សម-រង្ស៊ី, កឹម-សុខា ដែលជាកូនឆ្កែឆ្កួត ស្តូមកើតស្រែងនោះឯង។

យើងមិនប្រដូច ទុច្ចរិតទាំងពីរក្បាលនេះ ជាជនក្បត់ជាតិទេ ព្រោះជនក្បត់ជាតិ វានៅមានខួរវាជាអមនុស្ស ជ្រើសរើសគោលវិធីក្បត់ជាតិវា ជាឧបាយកលសំរាប់បោកប្រាស់ មិនមែនជ្រើសរើស គោលវិធីដ៏កំរោល ហោចល្អោញ (extrêmement rare)ដូចតិរច្ឆានបែបនេះឡើយ។

មួយវិញទៀត ក្នុងកិច្ចព្រមព្រៀងដ៏ចង្រៃនេះ តម្រូវឲគណបក្សសង្គ្រោះចោរ ធ្វើការធានាជាតុណ្ហី (tacite) ដល់គណបក្សចោរលួចជាតិ នូវការបន្ទប់បង្អាក់ (obstruction) គ្រប់បាតុកម្មរបស់អ្នកស្នេហាជាតិ ប្រឆាំងនឹងអំពើអយុត្តិធម៌ និង របបផ្តាច់ការ។ ក្នុងលក្ខណៈនេះ គណបក្សសង្គ្រោះចោរ បានក្លាយជាកងរក្សាសន្តិសុខឲ ហ៊ុន-សែន និង អាជ្ញាធរស្រមោលយួននៅស្រុកខ្មែរ។

ពន្លឺព្រះអារុណនៃគណបក្សសង្គ្រោះចោរ កំពុងតែបំភ្លឺបង្ហាញ នូវភាវគតិជាតិរច្ឆានរបស់ សម-រង្សី, កឹម-សុខា និង អ្នកដឹកនាំមួយចំនួនតូច នាំគ្នាដើរជាជួរជាហ្វូងសត្វទៅថ្វាយបង្គំស្តេចអាយ៉ង សុំការប្រសិទ្ធិពរ ដើម្បីឲពួកខ្លួនមានវិរិយៈ (ថាមពល) សំរាប់បំរើចោរ ឲបានប្រសិទ្ធិភាព ហើយនាំគ្នា បោះចោលអ្នកគាំទ្រខ្លួន, ម្ចាស់ឆ្នោត,ប្រជាពលរដ្ឋខ្មែរ ដូចសំរាម។ នេះហើយចរិតពួក «អា» តិរច្ឆាន។ តើចរិតបែបនេះវាខុសគ្នាត្រង់ណានឹង ហ៊ុន-សែន។

ជ័យជំនះយុត្តិធម៌ លើអយុត្តិធម៌, លទ្ធិប្រជាធិបតេយ្យ លើអំណាចផ្តាច់ការ វានៅតែមួយជំហាង (portée de main) សោះ ព្រោះខ្មែរមួយនគរ គេហ៊ានដើបប្រឆាំងតាមអំពើអហឹង្សា និងអំណាចផ្តាច់ការ គ្រាន់តែ ពួក «អា» តិរច្ឆាន ទាំងនោះ មានអំណត់ ប្រកាន់យកគោលជំហរដើម របស់ខ្លួន ជានិច្ចបន្តិច របបនេះវានឹងជួបប្រទះ ជាពុំខាន នឹងអាថ៌បញ្ហារបស់វា (problèmes principaux) ជាពុំខាន គឺ ៖ អត្ថិភាព នៃរបបផ្តាច់ការ និង ហេតុដែលនាំឲជឿ (crédibilité) នៃរបប លើឆាកអន្តរជាតិ។ តែខ្មែរគ្រប់គ្នាមើលឃើញហើយថា សេចក្តីឃ្លានងារ, សក្តិយស, សេចក្តីត្រូវការលុយកាក់ របស់ ពួក «អា» តិរច្ឆាន ទាំងនោះ វានាំឲពួកវា ត្រាច់រង្គាត់ដើរ ចូលទ្រង់ ហ៊ុន-សែន ឥតអៀនខ្មាស់អ្វីបន្តិឡើយ។

តែកិច្ចព្រមព្រៀងនេះ ក៏អាចជាភ័ព្វសំណាងចុងក្រោយបំផុតមួយដែរ សំរាប់ប្រជាពលរដ្ឋខ្មែរ ឲគាត់មើលឃើញដោយខ្លួនឯង នូវអំពើអសិរពិសនៃអ្នកដឹកនាំគណបក្សសង្គ្រោះចោរ វានាំគ្នាបែរមកខាំគាត់ ដែលជាអ្នកចិញ្ចឹមពួកវាទៅវិញ។ ការយល់ដឹងច្បាស់នេះ ត្រូវចាំបាច់

យកវាមកក្រងជាកម្លាំងជាតិ សំរាប់ប្រឆាំង នឹងការរួបរួមបំផ្លាញជាតិនៃជនទុច្ចរិត។ ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់អំណាច មានសន្តាបចិត្ត (emportement) ឬ កំហឹងចិត្ត ជាមូលដ្ឋាន នៃកម្លាំងតស៊ូ (force de résistance) ប្រឆាំង នឹងអំពើអយុត្តិធម៌ និង អំណាចផ្តាច់ការ ដែលជាភាពអាចបាន (possibilités) និង អានុភាពអាចធ្វើឲសម្រេចបាន (pouvoir acquis) កប់នៅក្នុងបញ្ញាពលរដ្ឋម្នាក់ៗ ដូច្នេះបើប្រជាពលរដ្ឋមានឆន្ទៈប្រកបដោយសេចក្តីក្លាហាន គឺច្បាស់ជាគ្មានកម្លាំងទុច្ចរិតណាមួយអាចឈ្នះ នូវកតិកានៃប្រជាជាតិនេះបាននោះឡើយ។ តែបើប្រជាពលរដ្ឋខ្មែរ គាត់គ្មានប្រតិកម្មអវិជ្ជមាន នឹងកិច្ចព្រមព្រៀងឧត្តមចង្រៃនេះទេ ហើយនាំគ្នាសម្ងំរស់យកសុខក្នុងទុគិតភាព និង សមធម៌ ការនេះ ជាការទទួលខុសត្រូវរបស់ខ្មែរម្នាក់ៗ នៅចំពោះការបន្តអត្តង្គត នៃប្រជាជាតិខ្មែរ ទាំងភាវរូបជាតិ (état physique du pays) និងភាវនៃពន្លឺបញ្ញាខ្មែរ (état des lumières du peuple khmer)។

តែយើងមានជំនឿជាក់ច្បាស់ថា យុវជនខ្មែរពុំអាចឈរមើលអំពើព្រៃផ្សៃបែបនេះបាននោះឡើយ និងនាំគ្នាបន្តការតស៊ូប្រឆាំងនឹងរបបផ្តាច់ការ ដែលមានគណបក្សសង្គ្រោះចោរជាឧបការីសកម្ម។ ការបន្តការតស៊ូក្នុងគោលការណ៍អហឹង្សា និង ខ្លួនទីពឹងខ្លួន វាមានការងាយស្រួលច្រើនណាស់ព្រោះអំណាចផ្តាច់ការ វាលែងមាន គណបក្សប្រឆាំងក្លែងក្លាយ សំរាប់ធ្វើជា វាំងននលំអលទ្ធិប្រជាធិបតេយ្យបានទៀតហើយ។ ទេសភាពនយោបាយ លែងមានភាពច្របូកច្របល់ មិនដឹងថា អ្នកណាជាមិត្ត ឬជាសត្រូវ នឹងលទ្ធិប្រជាធិបតេយ្យ។ លើកនេះខ្មែរដឹកច្បាស់ថា ជនណា ឬ ក្រុមណាជា សម្ពន្ធមិត្រ នឹងអំណាចផ្តាច់ការ គឺពិតជាសត្រូវនឹងប្រជាជាតិខ្មែរជាពុំខាន។

សំណួរសួរថា បាតុកម្មអ្នកគាំទ្រគណបក្សសង្គ្រោះជាតិ នៅបរទេស មានន័យអ្វីទៀត បើអ្នកដឹកនាំគណបក្សខ្លួន យល់ព្រមចូលរួមធ្វើសហការជាមួយគណបក្សចោរលួចជាតិទៅហើយ ?

**សង្ហា-ឧប**

**ថ្ងៃទី ២៣ កក្កដា ឆ្នាំ២០១៤**